Australian Government
Services Australia

KHMER

# Child Dental Benefits Schedule

Child Dental Benefits Schedule (CDBS) គ្រប ដណ្តប់មួយផ្នែក ឬតម្លៃពេញលេញនៃសេវាកម្មធ្មេញជាមូលដ្ឋានមួយចំនួនសម្រាប់កុមារដែលមានអាយុពី 0 ទៅ 17។

អ្នកអាចចូលទៅកាន់គេហទំព័រ **servicesaustralia.gov.au/childdental** ដើម្បីស្វែងយល់ថាតើយើងគ្របដណ្តប់អ្វីខ្លះ និងចំនួនប៉ុន្មាន។

## តើធ្វើដូចម្តេចដើម្បីដឹងថាតើអ្នកអាចមានសិទ្ធិទទួលបាន CDBS

អ្នកនឹងទទួលបានសំបុត្រមួយច្បាប់ពី Services Australia ប្រសិនបើកូនរបស់អ្នកអាចមានសិទ្ធិទទួលបាន CDBS។

វាមានសុពលភាពរយៈពេល 2 ឆ្នាំ។

កុមារ ឬក្មេងជំទង់អាចមានសិទ្ធិទទួលបាន CDBS ប្រសិនបើ៖

- ពួកគេមានអាយុពី 0 ទៅ 17 ឆ្នាំ យ៉ាងហោចណាស់មួយថ្ងៃនៃឆ្នាំប្រតិទិន
- ពួកគេមានឈ្មោះនៅលើប័ណ្ណ Medicare
- ពួកគេកំពុងទទួលបានប្រាក់ឧបត្ថម្ភ Centrelink ឬ Department of Veterans' Affairs (ក្រសួងកិច្ចការអតីតយុទ្ធជន) យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ឬមានឪពុកម្តាយ អ្នកថែទាំ ឬអាណាព្យាបាល ទទួលបានប្រាក់ឧបត្ថម្ភពីយើងយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។

ព័ត៌មានអំពីប្រាក់ឧបត្ថម្ភ Centrelink របស់អ្នក និងពី Department of Veterans' Affairs (ក្រសួងកិច្ចការអតីតយុទ្ធជន) ប្រាប់យើងថាតើអ្នកអាចទទួលបាន CDBS ឬអត់។

## ប្រភេទនៃសិទ្ធិទទួលប្រាក់ឧបត្ថម្ភ

| តើអ្នកណាទទួលបានប្រាក់ឧបត្ថម្ភ? | ប្រភេទនៃប្រាក់ឧបត្ថម្ភ |
|---|---|
| ឪពុកម្តាយ អ្នកថែទាំ ឬអាណាព្យាបាល | • Family Tax Benefit Part A<br>• Parenting Payment<br>• Double Orphan Pension |

•

| | |
|---|---|
| ក្មេង ឬក្មេងជំទង់ | • ABSTUDY<br>• Family Tax Benefit Part A<br>• Carer Payment<br>• Disability Support Pension<br>• Parenting Payment<br>• Special Benefit<br>• Youth Allowance<br>• ប្រាក់បំណាច់របស់ Department of Veterans' Affairs ប្រសិនបើអាយុ 16 ឆ្នាំ ដល់ 17 ឆ្នាំ |
| ដៃគូរបស់ក្មេងជំទង់ | • Family Tax Benefit Part A<br>• Parenting Payment |

## របៀបពិនិត្យមើលសមតុល្យ CDBS របស់អ្នក

អ្នកអាចពិនិត្យមើលចំនួនសមតុល្យ CDBS សម្រាប់កូនរបស់អ្នកដោយ៖

- សួរទន្តបណ្ឌិតរបស់អ្នក
- ប្រើ myGov អែប
- ចូលទៅកាន់ **my.gov.au** ហើយជ្រើសរើស Medicare បន្ទាប់មក 'History and statements' ('ប្រវត្តិ និងរបាយការណ៍') បន្ទាប់មក 'Child Dental Benefits Schedule' ('គម្រោងអត្ថប្រយោជន៍ថែទាំសុខភាពមាត់ធ្មេញសម្រាប់កុមារ')
- ហៅទូរសព្ទទៅលេខ **132 011**។ សូមអនុញ្ញាតឱ្យពួកយើងដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងរៀបចំជូនអ្នកដោយឥតគិតថ្លៃ។

## អ្វីដែលត្រូវបានគ្របដណ្តប់នៅក្រោម CDBS

CDBS គ្របដណ្តប់លើសេវាកម្មនានា រួមមាន៖

- ការពិនិត្យមើល
- ការថតកាំរស្មីអ៊ិច

- ការសម្អាត
- ការបំពេញប្រហោងធ្មេញ
- ឫសធ្មេញ
- ការដកធ្មេញ។

CDBS មិនគ្របដណ្តប់៖

- ការពត់តម្រង់ធ្មេញ
- ការងារកែសម្ផស្សធ្មេញ
- សេវាកម្មធ្មេញណាមួយដែលបានធ្វើនៅក្នុងមន្ទីរពេទ្យ។

សេវាកម្ម CDBS  មិនរាប់បញ្ចូលទៅក្នុង Medicare Safety Net ទេ។ អ្នកអាចចូលទៅកាន់ **servicesaustralia.gov.au/medicare-safety-nets** ដើម្បីស្វែងយល់បន្ថែមអំពី Medicare Safety Net ។

## របៀបប្រើ CDBS

ធ្វើការណាត់ជួបជាមួយទន្តបណ្ឌិត ហើយប្រាប់ពួកគេឱ្យដឹងថាអ្នកមានសិទ្ធិទទួលបាន CDBS។

នៅពេលណាត់ជួប ទន្តបណ្ឌិតត្រូវតែប្រាប់អ្នកពីសេវាកម្មនានាដែលកូនរបស់អ្នកត្រូវការ ហើយថាតើវានឹងត្រូវចំណាយអស់ប៉ុន្មាន មុនពេលពួកគេចាប់ផ្តើម។ ប្រសិនបើអ្នកយល់ព្រម អ្នកនឹងត្រូវចុះហត្ថលេខាលើទម្រង់បែបបទយល់ព្រម
មួយ។

## ការទាមទារអត្ថប្រយោជន៍នៅក្រោម CDBS

ប្រសិនបើទន្តបណ្ឌិតរបស់អ្នក bulk bills (គិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ) អ្នកមិនចាំបាច់ ធ្វើការទាមទារ ទេ។ Bulk billing (ការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ) មានន័យថា
អ្នកមិនចាំបាច់បង់ថ្លៃសេវាវេជ្ជសាស្ត្ររបស់អ្នកពីអ្នកជំនាញសុខភាពនោះទេ។

ប្រសិនបើទន្តបណ្ឌិតរបស់អ្នកមិន bulk bill (គិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ) ទេ អ្នកត្រូវបង់ថ្លៃសេវាកម្មនោះទៅឱ្យទន្តបណ្ឌិត ហើយបន្ទាប់មកទាមទារអត្ថប្រយោជន៍របស់អ្នកពីយើងវិញ។

អ្នកមិនអាចមិនទាមទារអត្ថប្រយោជន៍នៅក្រោម CDBS
និងពីក្រុមហ៊ុនធានារ៉ាប់រងសុខភាពឯកជនសម្រាប់សេវាកម្មធ្មេញដូចគ្នាបានទេ។

## សម្រាប់ព័ត៌មានបន្ថែម

- សូមចូលទៅកាន់ **servicesaustralia.gov.au/childdental** សម្រាប់ព័ត៌មានបន្ថែមជាភាសា English (ភាសាអង់គ្លេស)។
- ចូលទៅកាន់ **servicesaustralia.gov.au/yourlanguage** ជាកន្លែងដែលអ្នកអាចអាន ស្ដាប់ ឬមើលព័ត៌មានជាភាសារបស់អ្នក។
- ចូលទៅកាន់ **servicesaustralia.gov.au/forms** សម្រាប់បញ្ជីទម្រង់បែបបទរបស់យើងជាភាសា English (ភាសាអង់គ្លេស)។
- ទូរសព្ទទៅលេខ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នកអំពីប្រាក់ឧបត្ថម្ភ និងសេវាកម្មនានារបស់ Centrelink។
- ហៅទូរសព្ទលេខ **132 011** សម្រាប់ Medicare និងលេខ **131 272** សម្រាប់ Child Support (ការផ្គត់ផ្គង់កុមារ)។ សូមអនុញ្ញាតឱ្យពួកយើងដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងរៀបចំជូនអ្នកដោយឥតគិតថ្លៃ។

កំណត់ចំណាំ៖ ការហៅទូរសព្ទពីទូរសព្ទផ្ទះរបស់អ្នកទៅលេខ '13' ពីកន្លែងណាមួយនៅក្នុងប្រទេស Australia (ប្រទេសអូស្ត្រាលី) នឹងត្រូវបង់ថ្លៃតាមអត្រាថេរ។ អត្រានេះអាចខុសគ្នាពីអត្រាហៅទូរសព្ទនៅតាមតំបន់ និងរវាងក្រុមហ៊ុនផ្ដល់សេវាកម្មទូរសព្ទនានា។ ការហៅទូរសព្ទទៅលេខ '1800' ពីទូរសព្ទផ្ទះរបស់អ្នកគឺមិនគិតថ្លៃទេ។ ការហៅ ទូរសព្ទពីទូរសព្ទសាធារណៈ និងទូរសព្ទដៃ អាចគិតថ្លៃតាមពេលម៉ោងហៅ ហើយគិតថ្លៃតាមអត្រាខ្ពស់ជាង។

## ការបដិសេធ

ព័ត៌មានដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺមានគោលបំណងត្រឹមតែជាការណែនាំអំពីការទូទាត់ និងសេវាកម្មប៉ុណ្ណោះ។ វាជាទំនួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្តថាតើអ្នកចង់ដាក់ពាក្យសុំប្រាក់ឧបត្ថម្ភ និងធ្វើការដាក់ពាក្យឬអត់ ទាក់ទងនឹងកាលៈទេសៈជាក់លាក់របស់អ្នក។

Australian Government
Services Australia

ENGLISH

# Child Dental Benefits Schedule

The Child Dental Benefits Schedule (CDBS) covers part or the full cost of some basic dental services for children aged 0 to 17.

You can go to **servicesaustralia.gov.au/childdental** to find out what and how much we cover.

## How to know if you can get CDBS

You will get a letter from Services Australia if your child can get the CDBS.

It is valid for 2 years.

A child or teenager can get CDBS if:

- they are aged 0 to 17 years for at least one day of the calendar year
- they are on a Medicare card
- they are getting an eligible Centrelink or Department of Veterans' Affairs payment at least once a year, or have a parent, carer or guardian getting a payment from us at least once a year.

Information about your Centrelink payments and from the Department of Veterans' Affairs tells us if you can get CDBS or not.

### Types of eligible payments

| Who gets the payment? | The type of payment |
|---|---|
| Parent, carer or guardian | • Family Tax Benefit Part A<br>• Parenting Payment<br>• Double Orphan Pension |
| Child or teenager | • ABSTUDY<br>• Family Tax Benefit Part A<br>• Carer Payment<br>• Disability Support Pension<br>• Parenting Payment<br>• Special Benefit<br>• Youth Allowance<br>• Department of Veterans' Affairs allowances if aged 16 to 17 |
| Partner of teenager | • Family Tax Benefit Part A<br>• Parenting Payment |

## How to check your CDBS balance

You can check the CDBS balance amount for your child by:

- asking your dentist
- using the myGov app
- going to **my.gov.au** and selecting Medicare then 'History and statements', then 'Child Dental Benefits Schedule'
- calling **132 011**. Let us know if you need an interpreter and we will arrange one for free.

## What is covered under the CDBS

The CDBS covers services including:

- examinations
- X-rays
- cleaning
- fillings
- root canals
- extractions.

CDBS does not cover:

- orthodontic
- cosmetic dental work
- any dental services done in a hospital.

CDBS services do not count towards the Medicare Safety Net. You can go to **servicesaustralia.gov.au/medicare-safety-nets** to find out more about the Medicare Safety Net.

## How to use the CDBS

Make an appointment with a dentist and let them know you get the CDBS.

At the appointment, the dentist must tell you what services your child needs and how much it will cost before they start. If you agree you will need to sign a consent form.

## Claiming benefits under the CDBS

If your dentist bulk bills, you do not need to make a claim. Bulk billing means you do not have to pay for your medical service from a health professional.

If your dentist does not bulk bill, you need to pay the amount to the dentist and then claim your benefit from us.

You cannot claim a benefit under the CDBS and from a private health insurer for the same dental service.

## For more information

- Go to **servicesaustralia.gov.au/childdental** for more information in English.
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch information in your language.
- Go to **servicesaustralia.gov.au/forms** for a list of our forms in English.
- Call **131 202** to speak with us in your language about Centrelink payments and services.
- Call **132 011** for Medicare and **131 272** for Child Support. Let us know if you need an interpreter, and we will arrange one for free.

Note: calls from your home phone to '13' numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to '1800' numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It's your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.